**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# កំណត់ហេតុកិច្ចប្រជុំលើកទី២
# នៃក្រុមប្រឹក្សាយោបល់សម្រាប់ការងាររេដ+កម្ពុជា

*ឆ្នាំពីរពាន់ដប់បី ខែតុលា ថ្ងៃទីដប់ វេលាម៉ោងប្រាំបីនិងសាមសិបនាទី នៅសណ្ឋាគារអ៊ីម៉ាវ៉ារី រាជធានីភ្នំពេញ មានកិច្ចប្រជុំលើកទី២នៃក្រុមប្រឹក្សាយោបល់សម្រាប់ការងាររេដ+កម្ពុជា ដែលមានសមាជិកចូលរួមចំនួន១៨នាក់ រួមមានតំណាងមកពីៈ គ្រឹះស្ថានអប់រំ២នាក់ អង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ២នាក់ អង្គការមិនមែនរដ្ឋាភិបាលជាតិ២នាក់ សង្គមស៊ីវិល២នាក់ វិស័យឯកជន២នាក់ ជនជាតិដើមភាគតិច២នាក់ បណ្តាញសហគមន៍តំបន់ការពារ២នាក់ បណ្តាញសហគមន៍ព្រៃឈើ២នាក់ និងបណ្តាញសហគមន៍នេសាទ២នាក់(ម្នាក់ជាសមាជិកជំនួស)។ ដោយឡែកអ្នករៀបចំ និងអ្នកសង្កេតការណ៍មានចំនួន៧នាក់។*

*កិច្ចប្រជុំនេះដឹកនាំដោយសហប្រធាន២រូបគឺ លោក ឡាវ សេដ្ឋាផល ជាតំណាងលេខាធិការដ្ឋាន និងលោក ឈិត សំអាត ជាតំណាងសមាជិកក្រុមប្រឹក្សាយោបល់មកពីអង្គការមិនមែនរដ្ឋាភិបាលជាតិ។ សហប្រធានអង្គប្រជុំបានកំណត់លទ្ធផលកិច្ចប្រជុំថានឹងសម្រេចឲ្យបានៈ ១)លក្ខខន្តិកៈ ២)ជ្រើសរើសប្រធាន អនុប្រធាន និងលេខាធិការ ៣)ជ្រើសរើសអ្នកសម្របសម្រួលដឹកនាំកិច្ចប្រជុំខាងមុខ ៤)ជ្រើសរើសតំណាងចូលរួមប្រជុំជាមួយក្រុមការងាររេដ+ ៥)ជ្រើសរើសតំណាងចូលរួមជាសមាជិកក្រុមបច្ចេកទេស ៦)បង្កើតផែនការប្រឹក្សាយោបល់ និង៧)បង្កើតផែនការសកម្មភាព។*

*បន្ទាប់ពីណែនាំខ្លួនអ្នកចូលរួម កិច្ចប្រជុំបានចាប់ផ្តើមពិនិត្យ និងកែសម្រួលកំណត់ហេតុកិច្ចប្រជុំលើកទី១ កែសម្រួលរបៀបវារៈកិច្ចប្រជុំ និងបានដំណើរការដូចខាងក្រោមៈ*

## ***១)ការបង្កើតលក្ខខន្តិកៈក្រុមប្រឹក្សាយោបល់***

*ការពិភាក្សាលើកជាសំនួរថា ក្រុមប្រឹក្សាយោបល់ត្រូវមានលក្ខខន្តិកៈ ឬ មានត្រឹមលក្ខខណ្ឌការងារ និងបទបញ្ជាផ្ទៃក្នុង? ភាគច្រើនយល់ថាលក្ខខន្តិកៈតម្រូវឲ្យមានសម្រាប់សហគមន៍ ឬ សមាគម ដែលជានិតិបុគ្គលមានធនធានទ្រព្យសម្បត្តិ ខុសពីនេះ ក្រុមប្រឹក្សាយោបល់ ជាក្រុមអ្នកពាក់ព័ន្ធជួយផ្តល់យោបល់លើដំណើរការត្រៀមលក្ខណៈសម្រាប់រេដ+ប៉ុណ្ណោះ ដូច្នេះមិនចាំបាច់មានលក្ខខន្តិកៈទេ។*

❖ ***ការសម្រេចៈ*** *ក្រុមប្រឹក្សាយោបល់គឺមានត្រឹម លក្ខខណ្ឌការងារ និងបទបញ្ជាផ្ទៃក្នុងប៉ុណ្ណោះ។*

HY

❖ **សកម្មភាពបន្ត:** ដោយយោងតាមលទ្ធផលនៃកិច្ចប្រជុំលើកទី១ លេខាធិការដ្ឋាន នឹងជួយរៀបចំសេចក្តីព្រាងលក្ខខណ្ឌការងារ និងបទបញ្ជាផ្ទៃក្នុង ដើម្បីពិនិត្យសម្រេចក្នុងកិច្ចប្រជុំលើកទី៣។

## ២)ការជ្រើសរើសប្រធាន អនុប្រធាន និងលេខាធិការក្រុមប្រឹក្សាយោបល់

ការបោះឆ្នោតជ្រើសរើសប្រធាន អនុប្រធាន និងលេខាធិការ មិនអាចអនុវត្តបាន ដោយសារសមាជិកទាំងអស់មិនទាន់ស្គាល់គ្នាច្បាស់ ដូច្នេះដំណើរការ និង គោលការណ៍ជ្រើសរើសដែលបានអនុវត្តគឺៈ

- ការជ្រើសរើសធ្វើឡើងចំនួន៣លើក ដំបូងជ្រើសរើសប្រធាន បន្ទាប់មកជ្រើសរើសអនុប្រធាន និងចុងក្រោយជ្រើសរើសលេខាធិការ
- ប្រធាន អនុប្រធាន និងលេខាធិការ ត្រូវមានសមាសភាពជាតំណាងមកពីក្រុមផ្សេងគ្នា
- ការជ្រើសរើសបេក្ខភាពឈរឈ្មោះ គឺផ្អែកលើគោលការណ៍ស្ម័គ្រចិត្ត
- ការគាំទ្របេក្ខភាពឈរឈ្មោះត្រូវមានការឯកភាពមតិពីសមាជិកក្រុមប្រឹក្សាយោបល់
- ប្រធាន អនុប្រធាន និងលេខាធិការ ដែលបានជ្រើសរើស មានអាណត្តិមួយឆ្នាំ
- ដើម្បីជានាឲ្យមានសមធម៌ក្នុងការដឹកនាំ បេក្ខភាពឈរឈ្មោះអាណត្តិខាងមុខ ត្រូវមានសមាសភាពជាតំណាងមកពីក្រុមដែលមិនទាន់បាន ជ្រើសរើសក្នុងអាណត្តិកន្លងមក ។

❖ **លទ្ធផល និងការសម្រេច:**

- លោកសៀកសុផាត(Seak Sophat) តំណាងមកពីគ្រឹះស្ថានអប់រំ ត្រូវបានជ្រើសរើសជាប្រធាន
- លោក សា ថ្លៃ (Sa Thlay) តំណាងមកពីសហគមន៍ព្រៃឈើ ត្រូវបានជ្រើសរើសជាអនុប្រធាន
- លោកស្រី ហ៊ូ កល្យាណ (Hou Kalyan) តំណាងមកពីអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ ត្រូវបានជ្រើសរើសជាលេខាធិការ

## ៣)ជ្រើសរើសអ្នកសម្របសម្រួលដឹកនាំកិច្ចប្រជុំខាងមុខ

❖ **ការសម្រេច:** លោកវ៉ា មឿន(Va Moeurn) សមាជិកក្រុមប្រឹក្សាយោបល់មកពីអង្គការមិនមែនរដ្ឋាភិបាលជាតិ ដែលបានស្ម័គ្រចិត្ត នឹងទទួលកាតព្វកិច្ចជាអ្នកសម្របសម្រួលដឹកនាំកិច្ចប្រជុំលើកទី៣ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៣ ។

## ៤)ជ្រើសរើសតំណាងចូលរួមប្រជុំជាមួយក្រុមការងាររេដ+

ក្រុមការងាររេដ+កម្ពុជា នឹងរៀបចំកិច្ចប្រជុំលើកទី២ នៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៣។ តំណាងក្រុមប្រឹក្សាយោបល់ចូលរួមប្រជុំជាមួយក្រុមការងាររេដ+ ត្រូវមានចំណេះដឹង និងបទពិសោធន៍ពាក់ព័ន្ធនឹងប្រធានបទពិភាក្សាក្នុងកិច្ចប្រជុំក្រុមការងាររេដ+។

❖ *ការសម្រេច:* ដោយសារមិនទាន់ដឹងពីរបៀបវារៈ និងប្រធានបទពិភាក្សាក្នុងកិច្ចប្រជុំក្រុមការងារ រេដ+ ដូច្នេះការជ្រើសរើសតំណាងចូលរួមប្រជុំនេះ ត្រូវរង់ចាំរហូតដល់ថ្ងៃប្រជុំលើកទី៣ របស់ក្រុមប្រឹក្សាយោបល់ ដែលធ្វើឡើងនៅថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៣។

## ៥)ជ្រើសរើសតំណាងចូលរួមជាសមាជិកក្រុមបច្ចេកទេស

លក្ខខណ្ឌការងារនៃក្រុមបច្ចេកទេសរេដ+ទាំង៤ បានចែកជូនក្រុមប្រឹក្សាយោបល់ ដើម្បីពិនិត្យ និងយល់ច្បាស់ពីលក្ខខណ្ឌការងារនៃក្រុមបច្ចេកទេសរេដ+ទាំងនេះ។ យោងតាមលក្ខខណ្ឌការងារគឺត្រូវការសមាជិកក្រុមប្រឹក្សាយោបល់ចំនួន១៤នាក់ ចូលរួមជាសមាជិកក្រុមបច្ចេកទេសរេដ+ទាំង៤នេះ។ ការជ្រើសរើសក្រុមប្រឹក្សាយោបល់ ចូលរួមជាសមាជិកក្រុមបច្ចេកទេសរេដ+ គឺផ្អែកលើគោលការណ៍ស្ម័គ្រចិត្ត។ ប្រសិនបើអ្នកស្ម័គ្រចិត្តចូលរួមជាសមាជិកក្រុមបច្ចេកទេសមិនគ្រប់តាមតម្រូវការ សមាជិកម្នាក់អាចចូលរួមក្នុងក្រុមបច្ចេកទេស២ផ្សេងគ្នា។

❖ *លទ្ធផល និងការសម្រេច:*

- ក្រុមបច្ចេកទេសប្រព័ន្ធធានាសុវត្ថិភាព៖
  - ១)លោក សា ថ្ងៃ តំណាងមកពីសហគមន៍ព្រៃឈើ
  - ២)លោក ធឹត ឈន តំណាងមកពីជនជាតិដើមភាគតិច
  - ៣)លោក ស្មឿន បុរិវ័ន្ត តំណាងមកពីសង្គមស៊ីវិល(អង្គការមិនមែនរដ្ឋាភិបាលថ្នាក់ខេត្ត)
- ក្រុមបច្ចេកទេសចែករំលែកផលប្រយោជន៍៖
  - ១)លោក សុផា សុគន្ធណារុង តំណាងមកពីអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ
  - ២)លោក សៅ ជាង តំណាងមកពីសហគមន៍នេសាទ
  - ៣)លោក វង្ស តារា តំណាងមកពីសហគមន៍នេសាទ (សមាជិកជំនួស ឡុង សុចែត)
- ក្រុមបច្ចេកទេសអនុវត្តគម្រោងគំរូ៖
  - ១)លោកស្រី ហ៊ូ កល្យាណ តំណាងមកពីអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ
  - ២)លោក ស៊ុំ សុគន្ធ តំណាងមកពីវិស័យឯកជន
  - ៣)លោក រិទ្ធ ប៊ុនរឿន តំណាងមកពីសង្គមស៊ីវិល (អង្គការមិនមែនរដ្ឋាភិបាលថ្នាក់ខេត្ត)
- ក្រុមបច្ចេកទេសត្រួតពិនិត្យរាយការណ៍ ផ្ទៀងផ្ទាត់ កំរិតយោងនៃការបញ្ចេញឧស្ម័ន៖
  - ១)លោក គឹម សុបិន្ត តំណាងមកពីគ្រឹះស្ថានអប់រំ
  - ២)លោក ណុក វ៉ែន តំណាងមកពីជនជាតិដើមភាគតិច
  - ៣)លោក សា ថ្ងៃ តំណាងមកពីសហគមន៍ព្រៃឈើ
  - ៤)បណ្ឌិត សៀក សូផាត តំណាងមកពីគ្រឹះស្ថានអប់រំ

○ ៥)លោក ស្មឿន បុរីវ័ត្ន តំណាងមកពីសង្គមស៊ីវិល(អង្គការមិនមែនរដ្ឋាភិបាលថ្នាក់ខេត្ត)

**៦)បង្កើតផែនការប្រឹក្សាយោបល់**

គោលគំនិតស្តីពីផែនការប្រឹក្សាយោបល់ និងការចូលរួម បានចែកជូនក្រុមប្រឹក្សាយោបល់ ដើម្បីសិក្សាស្វែងយល់ពីទស្សនៈទាន និងគោលការណ៍នានា ដែលបានកំណត់នៅក្នុងផែនទីបង្ហាញផ្លូវរេដ+ ។ កិច្ចប្រជុំបានឯកភាពថា យន្តការចែករំលែកព័ត៌មាន និងផ្តល់យោបល់ត្រឡប់ ត្រូវជានាថាឲ្យបានទទួលទស្សន អ្នកពាក់ព័ន្ធនៅមូលដ្ឋាន។

**៧)បង្កើតផែនការសកម្មភាព**

RECOFTC នឹងផ្តល់ការបណ្តុះបណ្តាលជូនសមាជិកក្រុមប្រឹក្សាយោបល់ទាំងអស់ រយៈពេល៤ថ្ងៃ នៅដើមខែវិច្ឆិកា។ ការបណ្តុះបណ្តាលនេះនឹងមានប្រធានបទស្តីពីការបង្កើតផែនការសកម្មភាពសម្រាប់ក្រុមនីមួយៗ នៅថ្ងៃទី៤។

❖**ការសម្រេច:** ការបង្កើតផែនការសកម្មភាពរបស់ក្រុមនីមួយៗនឹងធ្វើឡើងនៅថ្ងៃបណ្តុះបណ្តាល។

**មតិបូកសរុប**

នៅចុងបញ្ចប់នៃកិច្ចប្រជុំ លោក ឡាវ សេដ្ឋាផល សហប្រធានអង្គប្រជុំ បានបូកសរុបលទ្ធផលតាមការសម្រេចខាងលើ និងវាយតម្លៃខ្ពស់ចំពោះលទ្ធផលដែលកិច្ចប្រជុំសម្រេចបាន និងបានថ្លែងអំណរគុណដ៏ជ្រាលជ្រៅ ចំពោះសមាជិកក្រុមប្រឹក្សាយោបល់ និងលេខាធិការដ្ឋាន ដែលបានចំណាយពេលវេលាដ៏មានតម្លៃចូលរួមក្នុងកិច្ចប្រជុំ និងបានប្រកាសបិទអង្គប្រជុំ នៅវេលាម៉ោងប្រាំគត់ នាថ្ងៃ ខែ ឆ្នាំ ដដែល។

**អ្នកធ្វើកំណត់ហេតុ**

**សហប្រធានអង្គប្រជុំ**

**តំណាងលេខាធិការដ្ឋាន ប្រធានក្រុមប្រឹក្សាយោបល់**

# កិច្ចប្រជុំលើកទី២ក្រុមប្រឹក្សាយោបល់រេដ+កម្ពុជា

***ទីកន្លែងប្រជុំ:*** *សណ្ឋាគារ អ៊ីម៉ាវ៉ារី រាជធានីភ្នំពេញ*

***កាលបរិច្ឆេទ:*** *ថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៣*

***ពេលវេលា:*** *៨:៣០-១៧:០០ នាទី រសៀល*

## របៀបវារៈកិច្ចប្រជុំ

| ពេលវេលា | ប្រធានបទពិភាក្សា | អ្នកសម្របសម្រួល |
|---|---|---|
| ០៨:០០-០៨:៣០ | - ចុះឈ្មោះអ្នកចូលរួម | - លោកស្រី ប៉ាន់ ធីតា |
| ០៨:៣០-០៩:៣០ | - ការណែនាំខ្លួនអ្នកចូលរួម<br>- ការពិនិត្យលើកំណត់ហេតុកិច្ចប្រជុំលើកទី១<br>- ការពិភាក្សារៀបចំលក្ខខន្តិកៈក្រុមប្រឹក្សាយោបល់ | - ប្រធានបណ្ដោះអាសន្ន<br><br>- លោក លន់ គឹមហ៊ី |
| ០៩:៣០-០៩:៤៥ | - សម្រាកអាហារសម្រន់ | - |
| ០៩:៤៥-១០:៣០ | - បន្តការពិភាក្សារៀបចំលក្ខខន្តិកៈក្រុមប្រឹក្សាយោបល់ | - លោក លន់ គឹមហ៊ី |
| ១០:៣០-១២:០០ | - ការពិភាក្សារៀបចំផែនការប្រឹក្សាយោបល់ | - តំណាងRECOFTC |
| ១២:០០-១៣:៣០ | - សម្រាកអាហារថ្ងៃត្រង់ | - |
| ១៣:៣០-១៤:៤៥ | - ផែនការការងាររបស់ក្រុមប្រឹក្សាយោបល់រេដ+កម្ពុជា | - តំណាងRECOFTC |
| ១៤:៤៥-១៥:០០ | - សម្រាកអាហារសម្រន់ | - |
| ១៥:០០-១៥:៣០ | - ការជ្រើសរើសប្រធានប្ដូរវេន | - ប្រធានបណ្ដោះអាសន្ន |
| ១៥:៣០-១៦:០០ | - ការជ្រើសរើសតំណាងចូលរួមកិច្ចប្រជុំក្រុមការងាររេដ+កម្ពុជា<br>- ការជ្រើសរើសតំណាងក្រុមប្រឹក្សាយោបល់ចូលរួមជាមួយក្រុមការងារបច្ចេកទេស | - ប្រធានបណ្ដោះអាសន្ន |
| ១៦:០០-១៦:៤៥ | - បញ្ហាផ្សេងៗ៖ | - ប្រធានបណ្ដោះអាសន្ន |
| ១៦:៤៥-១៧:០០ | - មតិបូកសរុបបិទអង្គប្រជុំ | - ប្រធានបណ្ដោះអាសន្ន |

HY

# កិច្ចប្រជុំលើកទី២ក្រុមប្រឹក្សាយោបល់រេដ+កម្ពុជា

*ថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៣ សណ្ឋាគារ អ៊ីម៉ាវ៉ារី រាជធានីភ្នំពេញ*

## បញ្ជីឈ្មោះអ្នកចូលរួម

| | | | | |
|---|---|---|---|---|
| **ក្រុមប្រឹក្សាយោបល់** | | | | |
| ១ | Mr. Kim Soben | គីមសុបិន្ត | គ្រឹះស្ថានអប់រំ | Royal University of Agriculture |
| ២ | Mr. Seak Sophat | សៀកសូផាត | គ្រឹះស្ថានអប់រំ | Royal University of Phnom Penh (RUPP) |
| ៣ | Mr. Sa Thlay | សាថ្លៃ | សហគមន៍ព្រៃឈើ | Oddor Meanchey Forestry Community |
| ៤ | Mr. Mao Ngar | ម៉ៅ ង៉ា | សហគមន៍ព្រៃឈើ | Kral Toeuk Community Forestry |
| ៥ | Mr. Vong Dara | វង្សតារា | សហគមន៍នេសាទ(សមាជិកជំនួស) | The Coalition of Cambodia Fishers (CCF) |
| ៦ | Mr. Sao Theang | សៅធាង | សហគមន៍នេសាទ | Chom Pou Khmao Community Fishery |
| ៧ | Mr. Prum Sarat | ព្រុំសារ៉ាត | សហគមន៍តំបន់ការពារ | Community Protected Areas Battambang |
| ៨ | Mr. Kean Hean | គានហ៊ាន | សហគមន៍តំបន់ការពារ | Phnom Pros Natural Community Protected Areas |
| ៩ | Mr. Rith Bunroeun | រិទ្ធ ប៊ុនរឿន | សង្គមស៊ីវិល | Action for Development (AFD ) |
| ១០ | Mr. Smeun Boreyroth | ស្មឿនបុរីរ័ត្ន | សង្គមស៊ីវិល | Children Development Association (CDA) |
| ១១ | Mr. Nok Ven | ណាក់ វ៉ែន | ជនជាតិដើមភាគតិច | Indigenous People (IP) Mondulkiri Province |
| ១២ | Mr. Chheurt Chhorn | ធឺតឈន | ជនជាតិដើមភាគតិច | Indigenous People (IP) Battambang Province |
| ១៣ | Mr. Sum Sokun | ស៊ុំ សុគន្ធ | វិស័យឯកជន | Lighting engineering & Solutions |
| ១៤ | Mr. Lu Chu-chang | លូ ឈូចាង | វិស័យឯកជន | Cambodia Timber Industry Association |
| ១៥ | Ms. Hou Kalyan | ហ៊ូ កល្យាណ | អង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ | RECOFTC |
| ១៦ | Mr. Sopha Sokun Narong | សុផា សុគន្ធ ណារុង | អង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ | WCS |
| ១៧ | Mr. Va Moeurn | វ៉ា មឿន | អង្គការមិនមែនរដ្ឋាភិបាលជាតិ | Mlup Baitong |
| ១៨ | Mr. Chhith Sam Ath | ឈិតសំអាត | អង្គការមិនមែនរដ្ឋាភិបាលជាតិ | NGO Forum on Cambodia |
| **អ្នករៀបចំ និងផ្សេងៗ** | | | | |
| ១៩ | Mr. Lao Sethaphal | ឡាវ សេដ្ឋាផល | សហប្រធានអង្គប្រជុំ | រដ្ឋបាលព្រៃឈើ |
| ២០ | Mr. Lun Kimhy | លន់ គីមហ៊ី | អ្នកសម្របសម្រួល | លេខាធិការដ្ឋានរេដ+ |
| ២១ | Ms. Pan Thida | ប៉ាន់ ធីតា | អ្នករៀបចំ | លេខាធិការដ្ឋានរេដ+ |
| ២២ | Mr. Teng Huort | តេងហួត | អ្នករៀបចំ | លេខាធិការដ្ឋានរេដ+ |
| ២៣ | Ms. Meas Somonika | មាសសុម៉ូនីកា | អ្នករៀបចំ | លេខាធិការដ្ឋានរេដ+ |
| ២៤ | Ms. Teng Rithiny | តេងរិទ្ធីនី | អ្នកសង្កេតការណ៍ | NGO Forum on Cambodia |
| ២៥ | Ms. Lyda Ngin | ងិនលីដា | អ្នកសង្កេតការណ៍ | NGO Forum on Cambodia |
| ២៦ | Ms. Michelle | មីសែល | អ្នកបកប្រែឲ្យលោកលូ ឈូចាង | វិស័យឯកជន |

HY

# កិច្ចប្រជុំលើកទី២ក្រុមប្រឹក្សាយោបល់រេដ+កម្ពុជា

**ទីកន្លែងប្រជុំ:** សណ្ឋាគារ អ៊ីម៉ារ៉ារី រាជធានីភ្នំពេញ

**កាលបរិច្ឆេទ:** ថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៣

**ពេលវេលា:** ៨:៣០-១៧:០០ នាទី រសៀល

## របៀបវារៈកិច្ចប្រជុំ

| ពេលវេលា | ប្រធានបទពិភាក្សា | អ្នកសម្របសម្រួល |
|---|---|---|
| ០៨:០០-០៨:៣០ | - ចុះឈ្មោះអ្នកចូលរួម | - លោកស្រី ប៉ាន់ ធីតា |
| ០៨:៣០-០៩:៣០ | - ការណែនាំខ្លួនអ្នកចូលរួម<br>- ការពិនិត្យលើកំណត់ហេតុកិច្ចប្រជុំលើកទី១<br>- ការពិភាក្សារៀបចំលក្ខខន្តិកៈក្រុមប្រឹក្សាយោបល់ | - ប្រធានបណ្តោះអាសន្ន<br><br>- លោកលន់ គឹមហ៊ី |
| ០៩:៣០-០៩:៤៥ | - សម្រាកអាហារសម្រន់ | - |
| ០៩:៤៥-១០:៣០ | - បន្តការពិភាក្សារៀបចំលក្ខខន្តិកៈក្រុមប្រឹក្សាយោបល់ | - លោកលន់ គឹមហ៊ី |
| ១០:៣០-១២:០០ | - ការពិភាក្សារៀបចំផែនការប្រឹក្សាយោបល់ | - តំណាងRECOFTC |
| ១២:០០-១៣:៣០ | - សម្រាកអាហារថ្ងៃត្រង់ | - |
| ១៣:៣០-១៤:៤៥ | - ផែនការការងាររបស់ក្រុមប្រឹក្សាយោបល់រេដ+កម្ពុជា | - តំណាងRECOFTC |
| ១៤:៤៥-១៥:០០ | - សម្រាកអាហារសម្រន់ | - |
| ១៥:០០-១៥:៣០ | - ការជ្រើសរើសប្រធានប្តូរវេន | - ប្រធានបណ្តោះអាសន្ន |
| ១៥:៣០-១៦:០០ | - ការជ្រើសរើសតំណាងចូលរួមកិច្ចប្រជុំក្រុមការងាររេដ+កម្ពុជា<br>- ការជ្រើសរើសតំណាងក្រុមប្រឹក្សាយោបល់ចូលរួមជាមួយក្រុមការងារបច្ចេកទេស | - ប្រធានបណ្តោះអាសន្ន |
| ១៦:០០-១៦:៤៥ | - បញ្ហាផ្សេងៗ៖ | - ប្រធានបណ្តោះអាសន្ន |
| ១៦:៤៥-១៧:០០ | - មតិបូកសរុបបិទអង្គប្រជុំ | - ប្រធានបណ្តោះអាសន្ន |

# កិច្ចប្រជុំលើកទី២ក្រុមប្រឹក្សាយោបល់អេដ+កម្ពុជា

*ថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៣ សណ្ឋាគារ អ៊ីម៉ារ៉ាវី រាជធានីភ្នំពេញ*

## បញ្ជីឈ្មោះអ្នកចូលរួម

| | | | | |
|---|---|---|---|---|
| **ក្រុមប្រឹក្សាយោបល់** | | | | |
| ១ | Mr. Kim Soben | គឹមសុបិន្ត | គ្រឹះស្ថានអប់រំ | Royal University of Agriculture |
| ២ | Mr. Seak Sophat | សៀកសូផាត | គ្រឹះស្ថានអប់រំ | Royal University of Phnom Penh (RUPP) |
| ៣ | Mr. Sa Thlay | សាថ្លៃ | សហគមន៍ព្រៃឈើ | Oddor Meanchey Forestry Community |
| ៤ | Mr. Mao Ngar | ម៉ៅ ង៉ា | សហគមន៍ព្រៃឈើ | Kral Toeuk Community Forestry |
| ៥ | Mr. Vong Dara | វង្សតារា | សហគមន៍នេសាទ(សមាជិកជំនួស) | The Coalition of Cambodia Fishers (CCF) |
| ៦ | Mr. Sao Theang | សៅធាង | សហគមន៍នេសាទ | Chom Pou Khmao Community Fishery |
| ៧ | Mr. Prum Sarat | ព្រុំសារ៉ាត | សហគមន៍តំបន់ការពារ | Community Protected Areas Battambang |
| ៨ | Mr. Kean Hean | គានហ៊ាន | សហគមន៍តំបន់ការពារ | Phnom Pros Natural Community Protected Areas |
| ៩ | Mr. Rith Bunroeun | រឹទ្ធ ប៊ុនរឿន | សង្គមស៊ីវិល | Action for Development (AFD ) |
| ១០ | Mr. Smeun Boreyroth | ស្មឿនបុរីរ័ត្ន | សង្គមស៊ីវិល | Children Development Association (CDA) |
| ១១ | Mr. Nok Ven | ណក់ វ៉ែន | ជនជាតិដើមភាគតិច | Indigenous People (IP) Mondulkiri Province |
| ១២ | Mr. Chheurt Chhorn | ធឺតឈន | ជនជាតិដើមភាគតិច | Indigenous People (IP) Battambang Province |
| ១៣ | Mr. Sum Sokun | ស៊ុំ សុគន្ធ | វិស័យឯកជន | Lighting engineering & Solutions |
| ១៤ | Mr. Lu Chu-chang | លូ ឈូចាង | វិស័យឯកជន | Cambodia Timber Industry Association |
| ១៥ | Ms. Hou Kalyan | ហ៊ូ កល្យាណ | អង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ | RECOFTC |
| ១៦ | Mr. Sopha Sokun Narong | សុផា សុគន្ធ ណារុង | អង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ | WCS |
| ១៧ | Mr. Va Moeurn | វ៉ា មឿន | អង្គការមិនមែនរដ្ឋាភិបាលជាតិ | Mlup Baitong |
| ១៨ | Mr. Chhith Sam Ath | ឈិតសំអាត | អង្គការមិនមែនរដ្ឋាភិបាលជាតិ | NGO Forum on Cambodia |
| **អ្នករៀបចំ និងផ្សេងៗ** | | | | |
| ១៩ | Mr. Lao Sethaphal | ឡាវ សេដ្ឋាផល | សហប្រធានអង្គប្រជុំ | រដ្ឋបាលព្រៃឈើ |
| ២០ | Mr. Lun Kimhy | លន់ គឹមហ៊ី | អ្នកសម្របសម្រួល | លេខាធិការដ្ឋានរេដ+ |
| ២១ | Ms. Pan Thida | ប៉ាន់ ធីតា | អ្នករៀបចំ | លេខាធិការដ្ឋានរេដ+ |
| ២២ | Mr. Teng Huort | តេងហួត | អ្នករៀបចំ | លេខាធិការដ្ឋានរេដ+ |
| ២៣ | Ms. Meas Somonika | មាសសុម៉ូនីកា | អ្នករៀបចំ | លេខាធិការដ្ឋានរេដ+ |
| ២៤ | Ms. Teng Rithiny | តេងរិទ្ធីនី | អ្នកសង្កេតការណ៍ | NGO Forum on Cambodia |
| ២៥ | Ms. Lyda Ngin | ងិនលីដា | អ្នកសង្កេតការណ៍ | NGO Forum on Cambodia |
| ២៦ | Ms. Michelle | មីសែល | អ្នកបកប្រែឲ្យលោកលូ ឈូចាង | វិស័យឯកជន |